ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ: ០៤៧ កយ.ប្រក/២៥

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យដំណើរការអង្គភាពអាជ្ញាសាលានៅតាមសាលាដំបូងរាជធានី ខេត្ត

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង
- បានឃើញប្រកាសលេខ ៣០ កយប្រក/០៧ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា
- បានឃើញប្រកាសលេខ ០៤៣ កយ.ប្រក/២៥ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពអាជ្ញាសាលានៅតាមសាលាដំបូងរាជធានី ខេត្ត
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌

## សម្រេច

**ប្រការ១ .-**

ត្រូវបានដាក់ឱ្យដំណើរការអង្គភាពអាជ្ញាសាលានៅតាមសាលាដំបូងរាជធានី ខេត្ត ចំនួន ៨ (ប្រាំបី) ដូចខាងក្រោម៖

១. អង្គភាពអាជ្ញាសាលានៅសាលាដំបូងរាជធានីភ្នំពេញ
២. អង្គភាពអាជ្ញាសាលានៅសាលាដំបូងខេត្តកណ្ដាល
៣. អង្គភាពអាជ្ញាសាលានៅសាលាដំបូងខេត្តសៀមរាប
៤. អង្គភាពអាជ្ញាសាលានៅសាលាដំបូងខេត្តបាត់ដំបង
៥. អង្គភាពអាជ្ញាសាលានៅសាលាដំបូងខេត្តព្រះសីហនុ
៦. អង្គភាពអាជ្ញាសាលានៅសាលាដំបូងខេត្តបន្ទាយមានជ័យ
៧. អង្គភាពអាជ្ញាសាលានៅសាលាដំបូងខេត្តកំពង់ចាម
៨. អង្គភាពអាជ្ញាសាលានៅសាលាដំបូងខេត្តកំពង់ស្ពឺ។

អង្គភាពអាជ្ញាសាលានៅតាមសាលាដំបូងរាជធានី ខេត្ត ខាងលើនេះ ចាប់ផ្ដើមដំណើរការចាប់ពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៥ នេះតទៅ។

**ប្រការ២ .-**

អង្គភាពអាជ្ញាសាលានៅតាមសាលាដំបូងនីមួយៗ មានទីតាំងស្ថិតនៅតាមសាលាដំបូងនោះ និងមានសមត្ថកិច្ចពិនិត្យ គ្រប់គ្រង និងចាត់ចែងកិច្ចការដែលជាសមត្ថកិច្ចរបស់អាជ្ញាសាលា ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់សាលាដំបូងរាជធានី ខេត្ត ដែលអង្គភាពអាជ្ញាសាលានោះស្ថិតនៅ ស្របតាមការកំណត់របស់ច្បាប់ និងប្រកាសលេខ ០៤៣ កយ.ប្រក/២៥ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពអាជ្ញាសាលានៅតាមសាលាដំបូងរាជធានី ខេត្ត ព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។

**ប្រការ៣ .-**

ចំពោះសំណុំរឿងអនុវត្តដែលកំពុងស្ថិតក្នុងចំណាត់ការរបស់មន្ត្រីអាជ្ញាសាលា ឬមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា មុនកាលបរិច្ឆេទដាក់ឱ្យដំណើរការអង្គភាពអាជ្ញាសាលាដូចមានកំណត់ក្នុងប្រការ១ នៃប្រកាសនេះ ត្រូវបន្តចាត់ការដោយមន្ត្រីអាជ្ញាសាលា ឬមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះ ស្របតាមច្បាប់ និងនីតិវិធីជាធរមាន។

**ប្រការ៤ .-**

ចំពោះសាលាដំបូងដែលមិនទាន់មានអង្គភាពអាជ្ញាសាលា ត្រូវបន្តអនុវត្តតាមប្រកាសលេខ ៣០ កយប្រក/០៧ ចុះថ្ងៃ១៩ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា។

**ប្រការ៥ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៦កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មេសា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កើត រិទ្ធ

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ